**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Aug-2011, 14:39
CMS/CFO: Phok Chanthan

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ:

ភាគីដាក់ឯកសារ: សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ**

---

<u>ដាក់ដោយ</u>៖

**<u>សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី</u>៖**

ពេជ អង្គ

Ms. Elisabeth SIMONNEAU FORT

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

គង់ ពិសី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

**<u>នៅចំពោះមុខ</u>៖**

**<u>អង្គជំនុំជម្រះសាលាដំបូង</u>៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មណី

**<u>ផ្ញើជូន</u>៖**

**<u>ការិយាល័យសហព្រះរាជអាជ្ញា</u>៖**

ជា លាង

Andrew T. CAYLEY

សំ សុគង់

ស៊ិន សុវ៉ន

ទី ស្រ៊ីនណា

វ៉ែន ពៅ

យុង ផានិត

Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabé NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES NAPROUS
Nushin SARKARATI
Silke STUDZINSKY
Philippine SUTZ

យ៉េត ចរិយា

William SMITH

**<u>ជនជាប់ចោទ៖</u>**

ខៀវ សំផន

អៀង សារី

អៀង ធីរិទ្ធ

នួន ជា

**<u>សហមេធាវីការពារក្តី៖</u>**

សុន អរុណ

Michiel PESTMAN
Victor KOPPE

អាង ឧត្តម

Michael G. KARNAVAS

ផាត់ ពៅស៊ាង

Diana ELLIS

ស សូវ៉ាន

Jacques VERGES

## I. សាវតារ

១. នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព") បានដាក់សំណើសុំឱ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដូចដែលបានរៀបរាប់ស្របតាមលក្ខណៈរបស់វា ថាជាបទរំលោភសេពសន្ថវៈ ជាជាងថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត"។ ក.ស.ព ស្នើសុំឱ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអំពើរំលោភសេពសន្ថវៈដែលបានអនុម័តដោយអង្គបុរេជំនុំជម្រះ ("អ.ប.ជ") និងសុំឱ្យអនុវត្តការកំណត់បទចោទថ្មីនេះជំនួសឱ្យការកំណត់បទចោទដំបូង ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ដែលឆ្លុះបញ្ចាំងកាន់តែជាក់លាក់ថែមទៀតអំពីស្ថានភាពនៃព្យសនកម្មដែលបានកើតឡើង[1]។

២. នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") បានណែនាំឱ្យភាគីនានាធ្វើការឆ្លើយតបទៅនឹងសំណើរបស់ ក.ស.ព ត្រឹមថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១[2]។

## II. កំណត់សម្គាល់បឋម

៣. សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមចូលរួម និងគាំទ្រទឡ្ហីករណ៍នានារបស់ ក.ស.ព។ វាជាការត្រឹមត្រូវដែលថា អំពើ រំលោភសេពសន្ថវៈត្រូវបានបង្ហាញឱ្យឃើញកាន់តែច្បាស់ឡើងៗរួចហើយ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គិតត្រឹមឆ្នាំ ១៩៧៥ ដែលនៅពេលនោះ ជនជាប់ចោទអាចដឹងថាមានច្បាប់ចែងអំពីទង្វើរបស់ខ្លួន និងអាចប្រមើលមើលដឹងថាទង្វើរបស់ខ្លួនគឺជាបទឧក្រិដ្ឋ។

៤. បន្ថែមពីលើនេះ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមបន្ថែមនៅក្នុងសារណានេះនូវទឡ្ហីករណ៍បន្ថែមមួយចំនួន ដើម្បីគាំទ្រដល់ការអះអាងថា

---

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើរំលោភសេពសន្ថវៈថាជាបទរំលោភសេពសន្ថវៈ ជាជាងថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E99។ សេចក្តីសម្រេចលើសំណើសុំពន្យារពេល ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ E107។

[2] សេចក្តីសម្រេចលើសំណើសុំពន្យារពេល ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ E107។

អំពើរំលោភសេពសន្ថវៈ ត្រូវបានទទួលស្គាល់រួចហើយថាជាឧក្រិដ្ឋកម្មដែលស្ថិតក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានរាយឈ្មោះក្នុងបញ្ជីនៅក្នុងពេលពាក់ព័ន្ធ។ គោលការណ៍នីត្យានុកូលភាពមិនត្រូវបានរំលោភបំពានដោយច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[3] និងការកំណត់បទចោទ នៃអំពើរំលោភសេពសន្ថវៈ នាពេលក្រោយមកទៀតថាជាបទល្មើសដែលបានលើកឡើង ដែលស្ថិតនៅក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ។

៥. សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងប្រើពាក្យថា "ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ" ជំនួសឱ្យពាក្យថា "បទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍" ដែលត្រូវបានប្រើនៅក្នុងដីកាដំណោះស្រាយ។ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថា ពាក្យថា "បទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍" មិនតំណាងឱ្យបានគ្រប់គ្រាន់នូវភាពមិនស្របច្បាប់ ភាពប្រាកដប្រជា និងស្ថានទម្ងន់នៃការប្រព្រឹត្តដែលបានបង្កើតជាបទឧក្រិដ្ឋនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនោះឡើយ។ ពាក្យថា "បទបញ្ជានៃការរៀបអាពាហ៍ពិពាហ៍" ដូចដែលសហចៅក្រមស៊ើបអង្កេតបានប្រើ បានធ្វើឱ្យព្យសនកម្មដែលជនរងគ្រោះនៃបទឧក្រិដ្ឋនេះបានទទួលរងប្រែក្លាយជាមិនសំខាន់។ ត្រឹមតែជា "បទបញ្ជា" មិនបង្ហាញច្បាស់លាស់អំពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះទេ។

## III. ឧទ្ធរណ៍

*ការរីកចម្រើន និងគោលបំណងនៃការបង្កើតឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ*

៦. ប្រវត្តិនៃច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាម និងបញ្ញត្តិទាំងឡាយរបស់ច្បាប់ និងទំនៀមទម្លាប់ទាំងនោះអាចត្រូវបានតាមដានចាប់តាំងពីសតវត្សរ៍ទី ១៩ មក[4]។ ការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ អាចត្រូវ

[3] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ មាត្រា ៥ ចែងថា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងទៅលើប្រជាជនស៊ីវិល... ដូចជា...ការរំលោភលើផ្លូវភេទ"។

[4] *សូមមើល* សន្និសីទសន្តិភាពទីក្រុងឡាអេ ឆ្នាំ ១៨៩៩ និងឆ្នាំ ១៩០៧ បានផ្តល់លទ្ធផលនៅក្នុងអនុសញ្ញាអន្តរជាតិលើកទី១៣។ អនុសញ្ញាទីក្រុងឡាអេចែងពីការប្រើប្រាស់អាវុធ និងវិធីសាស្ត្រទាំងឡាយនៃការធ្វើសង្គ្រាម។ អនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៨៦៤ ដែលត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ ១៩០៦ ពាក់ព័ន្ធនឹងការការពារបុគ្គលប្រឆាំងនឹងការប្រើប្រាស់កម្លាំងដោយរំលោភបំពាន។

បានលើកឡើងថាជាឧក្រិដ្ឋកម្មសង្គ្រាម។ ជាសំខាន់ *ក្រុមដែលជាគោលដៅត្រូវការពារ* នៃឧក្រិដ្ឋកម្មសង្គ្រាម គឺយុទ្ធជនជាខ្មាំងសត្រូវ និងប្រជាជនស៊ីវិលនៃបក្សប្រឆាំងដែលត្រូតត្រាទឹកដី ឬជនទាំងឡាយនៅក្នុងជំរំឃុំឃាំង ឬនៅក្នុងបន្ទាយឃុំឃាំងមនុស្ស។ និងបន្ថែមពីលើនេះ គឺអ្នកដែល ត្រូវទទួលបាននូវការការពារជាពិសេស ដូចជាបុគ្គលិកពេទ្យ និងបុគ្គលិកដែលចូលរួមនៅក្នុងអង្គការមនុស្សធម៌នានា។

៧. ការហាមឃាត់ជាក់លាក់នៃអំពើរំលោភសេពសន្ថវៈថាជាការរំលោភលើច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាម អាចត្រូវបានរកឃើញថាបានចុះកាលបរិច្ឆេទចាប់តាំងពីឆ្នាំ ១៨៦៣ នៅក្នុងសេចក្តីណែនាំដែលបានផ្តល់ឱ្យកងទ័ពរបស់សហរដ្ឋអាមេរិក នៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិល[5]។ ការហាមឃាត់អំពើរំលោភសេពសន្ថវៈនៅក្នុងបរិបទនៃច្បាប់ និងទំនៀមទម្លាប់នៃសង្គ្រាមត្រូវបានបង្កើតឡើងចាប់តាំងពីពេលនោះមក។

៨. វាជាការសំខាន់ដែលត្រូវកត់សម្គាល់ថា បទឧក្រិដ្ឋជាក់លាក់ និងធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តដោយពួកឈ្លានពានទៅលើប្រជាជនស៊ីវិលផ្ទាល់របស់ខ្លួន មិនត្រូវបានចែងនៅក្នុងបញ្ញត្តិច្បាប់ស្តីពីសង្គ្រាមនោះឡើយ។ ការខកខានមិនបានការពារប្រជាជនស៊ីវិលផ្ទាល់របស់ពួកឈ្លានពាន ត្រូវបានពិភាក្សាគ្នាជាលើកទីមួយ ពាក់ព័ន្ធទៅនឹងការសម្លាប់ជនជាតិអាមេនីជាទ្រង់ទ្រាយធំ ធ្វើឡើងដោយ Ottoman Empire។ ហេតុការណ៍នេះគឺជាលទ្ធផលនៅក្នុងការលើកឡើងដំបូងស្តីពីឧក្រិដ្ឋកម្ម *ថ្មី* ប្រឆាំងនឹង *មនុស្សជាតិ* និង*អារ្យធម៌* នៅក្នុងសេចក្តីប្រកាសរបស់រដ្ឋាភិបាលដែលជាសម្ព័ន្ធមិត្ត ប្រទេសបារាំង ប្រទេសអង់គ្លេស និងប្រទេសរុស្ស៊ី គិតត្រឹមថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩១៥[6]។

---

អនុសញ្ញាទាំងពីរនេះគឺជាបញ្ញត្តិច្បាប់ដំបូងនៃច្បាប់មនុស្សធម៌ដែលត្រូវបានចងក្រងតែមួយ ដែលចូលជាធរមាននៅពេលចាប់ផ្តើមសង្គ្រាមលោកលើកទី១ ។

សម្រាប់សេចក្តីសង្ខេបអំពីបញ្ញត្តិច្បាប់ទាំងមូល សូមមើល http://www.icrc.org/ihl.nsf/INTRO?OpenView ។

[5] សេចក្តីណែនាំសម្រាប់រដ្ឋាភិបាលនៃកងទ័ពរបស់សហរដ្ឋអាមេរិកនៅក្នុងសមរភូមិ (Lieber Code) ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៨៦៣ មាត្រា ៤៤។

[6] សូមមើល Cassese, Antonio ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បោះពុម្ពផ្សាយលើកទីពីរ សៀវភៅ Oxford (ឆ្នាំ ២០០៨) ទំព័រ ១០១ យោងនៅក្នុងជើងទំព័រលេខ៥។ សន្ធិសញ្ញាសន្តិភាពនៃ Sèvres ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩២០ នៅ http://www.hri.org/docs/sevres/ ដែលមានបំណងបង្កើតតុលាការមួយសម្រាប់កាត់ទោសឧក្រិដ្ឋកម្មជាច្រើន មិនត្រូវបានអនុម័ត នោះទេ។ ការអនុម័តសន្ធិចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា
សុំឱ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

៩. នៅឆ្នាំ ១៩១៩ គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកបង្កើតសង្គ្រាម និងស្តីពីការអនុវត្តទណ្ឌកម្ម[7] បានរាយឈ្មោះអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្ម (*សង្គ្រាម*) ជាន់ខ្ពស់មួយ[8]។ សហរដ្ឋអាមេរិកបានជំទាស់ដោយជោគជ័យទៅនឹងគោលជំហររបស់គណៈកម្មការ ដោយផ្អែកលើមូលដ្ឋាននៃ "ភាពជាក់លាក់ និងអត្ថន័យមិនប្រាកដនៃពាក្យថា *ច្បាប់របស់មនុស្សជាតិ*"[9]។ ភាពស្មុគស្មាញនៃទំនងជាដើមហេតុនៃការមិនពេញចិត្ត ក្នុងការធ្វើអន្តរាគមទៅក្នុងបូរណភាពទឹកដីរបស់រដ្ឋមួយ ដើម្បីដោះស្រាយបទឧក្រិដ្ឋដ៏ព្រៃផ្សៃទាំងឡាយដែលត្រូវបានប្រព្រឹត្តលើប្រជាជនផ្ទាល់របស់ខ្លួន។

១០. សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លើកឡើងថា គណៈកម្មការបានបញ្ជាក់អំពីការយល់ព្រមទាំងស្រុង និងអំពីទស្សនៈយល់ឃើញរបស់សហគមន៍អន្តរជាតិ។ បទរំលោភសេពសន្ថវៈត្រូវបានរាយឈ្មោះជាបទឧក្រិដ្ឋទីប្រាំ ក្នុងចំណោមបទឧក្រិដ្ឋចំនួន ៣២ ដែលត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋជាក់លាក់ និងធ្ងន់ធ្ងរជាងគេ។ រហូតដល់ឆ្នាំ ១៩១៩ ទោះបីជាក្រុមគោលដៅ ត្រូវបានកម្រិតត្រឹមក្រុមដែលត្រូវការពារនៅក្នុងអំឡុងពេលសង្គ្រាម (ដោយសារហេតុផលនយោបាយ) ក៏ដោយ ក៏ពុំមានឧបសគ្គអ្វីចំពោះការអនុម័តបញ្ជីឈ្មោះបទ ឧក្រិដ្ឋដដែលសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានបង្ហាញនៅពេលក្រោយមកទៀតនោះឡើយ។ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាទូទៅលើកឡើងពីឧក្រិដ្ឋកម្មជាក់លាក់ និង

---

សញ្ញាសន្តិភាពនៃ Lausanne នៅពេលក្រោយមកទៀត នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩២៣ បានផ្តល់ការ អនុគ្រោះទោសសម្រាប់បទឧក្រិដ្ឋទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅចន្លោះឆ្នាំ ១៩១៤ និងឆ្នាំ ១៩២២។

[7] គណៈកម្មការស្តីពីការទទួលខុសត្រូវរបស់អ្នកបង្កើតសង្គ្រាម និងស្តីពីការអនុវត្តទណ្ឌកម្ម បានរាយការណ៍នៅក្នុងសន្និសីទសន្តិភាពបឋម នៅទីក្រុង Versailles នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩១៩ បានបោះពុម្ពផ្សាយឡើងវិញនៅក្នុងកាសែតអាមេរិកនៃច្បាប់អន្តរជាតិ [AJIL] ១៤, ៩៥-១៥៤។ តុលាការដែលគេបានគិតមិនត្រូវបានបង្កើតឡើងនោះទេ។ ផ្ទុយទៅវិញ ការចោទប្រកាន់ពីឧក្រិដ្ឋកម្មសង្គ្រាមត្រូវបានបញ្ជូនទៅតុលាការអាល្លឺម៉ង់នៅពេលមានការព្រមព្រៀងផ្នែកនយោបាយ និងដោយសារតែទំនាស់ផលប្រយោជន៍រវាងប្រទេសសម្ព័ន្ធមិត្ត។ សូមមើល Kai Ambos, Internationales Strafrecht, ទំព័រ ៩០ កថាខណ្ឌ ៤ ដល់៥។

[8] សូមមើល 14 AJIL ទំព័រ ១១៥។

[9] Banteakas, Ilias និង Nash, Susan, ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ បោះពុម្ពផ្សាយលើកទីបី Routledge Cavendish (ឆ្នាំ ២០០៧) ត្រង់ទំព័រ ១២៦។

ធ្ងន់ធ្ងរបំផុត។ ហេតុដូច្នេះ បញ្ជីឈ្មោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវតែបញ្ចូលនូវបទរំលោភសេពសន្ថវៈផ្សេងពីគ្នា និងជាលក្ខណៈបុគ្គល។

១១. ក្រោយសង្គ្រាមលោកលើកទី២ សម្រាប់លើកទីមួយនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានបង្កើត និងបានក្លាយជាផ្នែកមួយនៃយុត្តាធិការលើរឿងក្តីនៃធម្មនុញ្ញតុលាការយោធាអន្តរជាតិ ("IMT")[10]។ មូលហេតុសម្រាប់ការបង្កើតប្រភេទថ្មីនៃបទឧក្រិដ្ឋនានា គឺដោយសារតែសម្ព័ន្ធមិត្តទាំងឡាយបានដឹងថា ឧក្រិដ្ឋកម្មនៃសង្គ្រាមបានការពារតែប្រជាជនប្រឆាំង និងប្រជាជនជាខ្មាំងសត្រូវតែប៉ុណ្ណោះ ប៉ុន្តែមិនបានគ្របដណ្តប់លើឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តឡើងដោយពួកណាស៊ី (អាល្លឺម៉ង់) ប្រឆាំងនឹងប្រជាជនផ្ទាល់របស់ខ្លួនឡើយ។ មូលហេតុនេះនឹងមិនបញ្ចូលនូវឧក្រិដ្ឋកម្មរបស់ពួកណាហ្ស៊ីប្រឆាំងនឹងជនជាតិជ្វីហ្វអាល្លឺម៉ង់ និងក្រុមដែលត្រូវបានធ្វើទុក្ខបុកម្នេញផ្សេងទៀតដែលស្ថិតក្នុងចំណោមប្រជាជនអាល្លឺម៉ង់ ដូចជា ពួក Roma/Sinti ពួកកុម្មុយនីស្តសមាជិកសហព័ន្ធពាណិជ្ជកម្ម ពួកសង្គមនិយម "ពួកសមាសធាតុអាក្រក់ និងគ្មានប្រយោជន៍" សមាជិកព្រះវិហារ និងអ្នកប្រតិព័ទ្ធភេទដូចគ្នាជាដើម។ បន្ថែមពីលើនេះ មូលហេតុនេះនឹងមិនបញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជាតិរបស់រដ្ឋបរទេស ដែលមិនស្ថិតក្រោមការត្រួតត្រា ជាផ្លូវការនោះទេ ប៉ុន្តែរដ្ឋបរទេសដែល "ជាឧបសម្ព័ន្ធ" ដូចជា ប្រទេសអូស្ត្រាលី និងជនជាតិជ្វីហ្វ ដែលគ្មានរដ្ឋ និងពួក Roma/Sinti។ ការបង្កើតក្របខ័ណ្ឌគតិយុត្តបែបនេះអាចនាំឱ្យមានលទ្ធផលដែលមិនសមហេតុផល គឺថា ការសម្លាប់ជនជាតិជ្វីហ្វប៉ូឡូញនឹងត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មសង្គ្រាម ខណៈពេលដែលអំពើដូចគ្នានេះធ្វើទៅលើជនជាតិជ្វីហ្វអាល្លឺម៉ង់នឹងមិនត្រូវបានដាក់ទោសឡើយ។

១២. ហេតុនេះ មូលហេតុទាំងនេះបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថ្មីមួយ ដែលមានគោលបំណងបំពេញចន្លោះប្រហោងនៅពេលដែល "មានតែ" ឧក្រិដ្ឋកម្មសង្គ្រាមប៉ុណ្ណោះនឹងត្រូវបានកាត់ទោស រីឯឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនរបស់ពួកណាស៊ីនាន ដែលធ្វើឡើងដោយពួកណាស៊ីនានខ្លួនឯងនឹងមិនត្រូវបានកាត់ទោសនោះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ចំណងទាក់ទងដែលមានស្រាប់រវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព គឺជា

---

[10] កិច្ចព្រមព្រៀងសម្រាប់ការចោទប្រកាន់ និងការដាក់ទោសឧក្រិដ្ឋជនសង្គ្រាមធំៗរបស់សម្ព័ន្ធមិត្តអឺរ៉ុប និងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ។ ទីក្រុងឡុងដ៍ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ១៩៤៥ នៅ ttp://www.icrc.org/ihl.nsf/FULL/350?OpenDocument.

លទ្ធផលនៃភាពស្មាក់ស្មើរក្នុងការចោទប្រកាន់ពីបទឧក្រិដ្ឋទាំងឡាយ ដែលត្រូវបានប្រព្រឹត្តឡើងមុនសង្គ្រាមបានចាប់ផ្តើម និងក្នុងការជ្រៀតជ្រែកចូលក្នុងបូរណភាពទឹកដី និងផលប្រយោជន៍របស់តតិយប្រទេស[11]។

១៣. លក្ខខណ្ឌកំណត់បន្ថែមនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺ "ការវាយប្រហារដែលមានលក្ខណៈទូលំទូលាយ និងមានលក្ខណៈជាប្រព័ន្ធប្រឆាំងនឹងប្រជាជនស៊ីវិល" ដែលមិនបានបញ្ចូលនូវអំពើនានាដែលមានលក្ខណៈបុគ្គលតែម្នាក់ ឲ្យស្ថិតនៅក្នុងវិសាលភាពនៃបទឧក្រិដ្ឋនេះ ឬឲ្យទទួលបានការកាត់ទោសនៅក្នុងតុលាការក្នុងស្រុកនោះទេ។

១៤. សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានតុលាការយោធាអន្តរជាតិចាត់ទុកថាជាបទឧក្រិដ្ឋមានលក្ខណៈប្រហាក់ប្រហែលគ្នា។ គេអាចកត់សម្គាល់ឃើញថា តុលាការយោធាអន្តរជាតិ "បានជៀសវាងមិនកំណត់ឲ្យបានច្បាស់លាស់នូវការបែងចែកដាច់ពីគ្នារវាងឧក្រិដ្ឋកម្មទាំងពីរប្រភេទ [ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ] តែផ្ទុយទៅវិញ បែរជាសុខចិត្តយល់ឃើញថា នៅក្នុងរឿងក្តីជាច្រើន ជនជាប់ចោទអាចទទួលខុសត្រូវចំពោះបទល្មើសទាំងពីរ"[12]។

១៥. ឧក្រិដ្ឋកម្មទាំងឡាយដែលទីបញ្ចប់ត្រូវបានរាប់ថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ ស្របជាមួយនឹងការរីកចម្រើន គេត្រូវតែយល់ឃើញថា "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ" ជាឧក្រិដ្ឋកម្មដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មសង្គ្រាម ប៉ុន្តែត្រូវបានកំណត់គោលដៅទៅលើក្រុមមនុស្សផ្សេងគ្នា។ ដោយពិនិត្យមើលលើបរិបទ និងសេចក្តីថ្លែងបញ្ចេញយោបល់ជាប្រវត្តិសាស្ត្រនៅក្រោយសង្គ្រាមលោកលើកទី២ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ការខកខានក្នុងការវាយឈ្មោះឧក្រិដ្ឋកម្មផ្សេងៗទៀត ដូចជាអំពើធ្វើទារុណកម្ម អំពើឃុំឃាំងមនុស្ស និងអំពើរំលោភផ្លូវភេទ ជាដើម មិនមែនជាការបង្ហាញថា ឧក្រិដ្ឋកម្មទាំងអស់នេះមិនត្រូវបានរួមបញ្ចូលនោះទេ។ ពាក្យពេចន៍របស់ធម្មនុញ្ញ

[11] សូមមើល Cassese ត្រង់ទំព័រ ១០៣ ដល់ ១០៤។

[12] សូមមើល Cassese ត្រង់ទំព័រ ១០៦។

ដែលចែងថា "[...] ពោលគឺ ការសម្លាប់មនុស្ស ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស [...]" (*សេចក្តីបញ្ជាក់បន្ថែម*) លើកឡើងថា បញ្ជីឈ្មោះនេះមិនពិនិត្យឲ្យបានជិតដល់នោះទេ រីឯឧក្រិដ្ឋកម្មដែលបានរាយឈ្មោះទាំងឡាយគឺគ្រាន់តែជាឧទាហរណ៍ស្តីពីឧក្រិដ្ឋកម្មជាក់លាក់ និងធ្ងន់ធ្ងរប៉ុណ្ណោះ - ពីព្រោះឧក្រិដ្ឋកម្មទាំងនេះត្រូវបានរាយឈ្មោះ នៅក្នុងបញ្ជីរបស់គណៈកម្មការឆ្នាំ ១៩១៩។

១៦. លើសពីនេះទៀត បទរំលោភសេពសន្ថវៈគួរតែត្រូវបានបញ្ចូលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពីព្រោះអ្នកធ្វើសេចក្តីព្រាងចង់បញ្ចូលឧក្រិដ្ឋកម្មដែលព្រៃផ្សៃជាងគេបំផុតលើមនុស្សជាតិ ដែលជាឧក្រិដ្ឋកម្មដែល "អាចផ្តន្ទាទោសបានតាមក្រមព្រហ្មទណ្ឌរបស់ប្រជាជាតិទាំងអស់"[13]។ យ៉ាងគួរឲ្យចាប់អារម្មណ៍ មេធាវីការពារក្តីនៅក្នុងសវនាការ Nuremberg មិនបានជំទាស់ទៅនឹងការអនុវត្តប្រតិសកម្ម នៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ គ្រាន់តែបានយោងទៅលើភាពមិនប្រតិសកម្មនៃឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាពប៉ុណ្ណោះ។ វាពិតជាច្បាស់លាស់ណាស់ថា អំពើរំលោភសេពសន្ថវៈនៅពេលនោះ គឺជាបទល្មើសមួយដែលប្រជាជាតិទាំងអស់បានលើកឡើងថា អាចទទួលការផ្តន្ទាទោសបាននៅក្នុងយុត្តាធិការជាតិរបស់ខ្លួន និងត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មជាក់លាក់ និងធ្ងន់ធ្ងរមួយ។

១៧. សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើការកត់សម្គាល់ថា បញ្ជីឈ្មោះ "សមាជិក និងសមាជិកាជាជម្រើសរបស់តុលាការ" និង "មេធាវីដើមចោទ" ពុំមានអ្នកចូលរួមជាស្ត្រីភេទទេ។ "បញ្ជីឈ្មោះរបស់អ្នកតំណាង និងជំនួយការ" របស់សន្និសីទអន្តរជាតិស្តីពីការជំនុំជម្រះក្តីយោធា ទីក្រុងឡុងដ៍ ឆ្នាំ ១៩៤៥ បានរាយឈ្មោះស្ត្រីតែពីររូបប៉ុណ្ណោះ ក្នុងនាមពួកគាត់ជាលេខាធិការ[14]។ ការកត់សម្គាល់នេះអាចជាកត្តាសំខាន់មួយនៅក្នុងការមិនបញ្ចូល បទរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មមួយដែលត្រូវបានរាយឈ្មោះថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក៏ដូចជាអត្ថិភាពដែលបានផ្តល់ឲ្យឧក្រិដ្ឋកម្មដែលត្រូវបានចុះក្នុងបញ្ជីផ្សេងទៀត ដោយធ្វេសប្រហែស និងជាបន្តបន្ទាប់ផងដែរ។

---

[13] សូមមើល ការដកស្រង់នៅក្នុងជើងទំព័រ ២១ Cassese ត្រង់ទំព័រ ១០៦។

[14] ត្រូវបានដកស្រង់នៅក្នុង Askin, Kelly *ឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងស្ត្រីភេទៈ ការកាត់ទោសនៅក្នុងតុលាការឧក្រិដ្ឋកម្មសង្គ្រាមអន្តរជាតិ* Cambridge បណ្តុំៈ ច្បាប់អន្តរជាតិ Kluwer (ឆ្នាំ ១៩៩៧) ជើងទំព័រលេខ ៣៤៣។

១៨. សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និងសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី យល់ឃើញថា បញ្ជីឈ្មោះនៃឧក្រិដ្ឋកម្មសង្គ្រាមដែលត្រូវបានបង្កើតឡើង ដែលចុះកាលបរិច្ឆេទឆ្នាំ ១៩១៩ អនុវត្តចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានបង្កើតឡើងថ្មីៗ។ បញ្ជីនេះទទួលបានការគាំទ្រតាមរយៈអង្គហេតុដែលថា រយៈពេលបួនខែបន្ទាប់ពីធម្មនុញ្ញ Nuremberg ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង[15] (“CCL 10”) ត្រូវបានអនុម័ត និងបានបញ្ចូលអំពើរំលោភសេពសន្ថវៈ អំពើធ្វើទារុណកម្ម និងអំពើឃុំឃាំងមនុស្ស ថាជាឧក្រិដ្ឋកម្មដែលបានរាយឈ្មោះនៅក្នុងបញ្ជីដែលស្ថិតនៅក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ នៅក្នុងអំឡុងពេលបួនខែនេះ ពុំមានការរីកចម្រើននៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលនឹងពន្យល់អំពីការប្រែប្រួលនេះទេ ដូច្នេះហើយ គេអាចសន្និដ្ឋានបានថា ការមិនបញ្ចូលអំពើរំលោភសេពសន្ថវៈនៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ មិនមែនជាការបញ្ជាក់ថា អំពើរំលោភសេពសន្ថវៈមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅខែ សីហា ឆ្នាំ ១៩៤៥ នោះទេ។ ពុំមាននរណាម្នាក់នឹងធ្វើការតវ៉ាខ្លាំងថា អំពើធ្វើទារុណកម្ម និងអំពើឃុំឃាំងមនុស្ស មិនត្រូវយកទៅពិចារណាឃើញថា ជាបទល្មើសដែលត្រូវបានរាយឈ្មោះក្នុងបញ្ជីដែលស្ថិតនៅក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយសារតែអំពើទាំងនេះមិនត្រូវបានចែងនៅក្នុងច្បាប់លក្ខន្តិកៈ Nuremberg នោះទេ។ ហេតុដូច្នេះ អំពើរំលោភសេពសន្ថវៈក៏ដូចគ្នាដែរ។

១៩. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ការមិនបញ្ចូលអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មដែលមាននៅក្នុងបញ្ជីក្រោមច្បាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ មិនមែនជាការបង្ហាញថា អំពើរំលោភសេពសន្ថវៈមិនត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ ប៉ុន្តែជាការឆ្លុះបញ្ចាំងពីអំពើធ្វើឡើងដោយធ្វេសប្រហែលមួយ។ អំពើរំលោភសេពសន្ថវៈត្រូវបានទទួលស្គាល់នៅក្នុងយុត្តាធិការជាតិនៅជុំវិញពិភពលោកថាជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរ និងព្រៃផ្សៃ និងត្រូវបានចុះក្នុងបញ្ជីថាជាឧក្រិដ្ឋកម្មសង្គ្រាមចាប់តាំងពីឆ្នាំ ១៩១៩ មកម្ល៉េះ។ គោលបំណងនៃប្រភេទដែលបានបង្កើតឡើងថ្មីៗនៃ “ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”

---

[15] សូមមើល មាត្រា ២ នៃច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ការផ្តន្ទាទោសជនដែលមានពិរុទ្ធភាពពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព និងប្រឆាំងនឹងមនុស្សជាតិ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៤៥ ក្រុមប្រឹក្សាគ្រប់គ្រងសារព័ត៌មានផ្លូវការរបស់អាល្លឺម៉ង់ ៥០-៥៥ (ឆ្នាំ ១៩៤៦) នៅ http://www1.umn.edu/humanrts/instree/ccno10.htm.។

គឺដើម្បីអនុញ្ញាតឱ្យមានការចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មដែលបានគូសបញ្ជាក់ដូចគ្នា ដែលត្រូវបានរាយឈ្មោះនៅក្នុងបញ្ជីថា ជាឧក្រិដ្ឋកម្មសង្គ្រាមដែលត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងក្រុមគោលដៅផ្សេងគ្នា។

***អំពើរំលោភសេពសន្ថវៈជាបទល្មើសមួយ ស្របតាមលក្ខណៈរបស់វា ដែលស្ថិតក្រោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងយុត្តាធិការជាតិ***

២០. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ការចោទប្រកាន់អំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានកើតឡើងរួចហើយនៅក្នុងយុត្តាធិការជាតិ នាដើមទសវត្សរ៍ឆ្នាំ១៩០០។

២១. នៅប្រទេសចិន តុលាការឧក្រិដ្ឋកម្មសង្គ្រាមមួយត្រូវបានបង្កើតឡើង តាមរយៈ "ច្បាប់គ្រប់គ្រងដណ្តប់លើការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម" ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៤៦[16]។ ក្នុងរបាយការណ៍ច្បាប់នៃគណៈកម្មការទទួលបន្ទុកឧក្រិដ្ឋកម្មសង្គ្រាម[17] វិសាលភាពនៃយុត្តាធិការជាកម្មវត្ថុត្រូវបានពណ៌នាដូចខាងក្រោម៖

> *"រាល់បទល្មើសដែលរាប់បញ្ចូលក្នុងមាត្រាII កថាខណ្ឌ៣នៃច្បាប់ចិន ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៤៦ ឆ្លើយតបជាស្មារតីជាមួយនឹងទស្សនាទាននៃ**ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ** ដោយវាទាក់ទិននឹងខ្លឹមសារនៃមាត្រា៦(គ)នៃធម្មនុញ្ញ Nuremberg មាត្រា៥(គ) នៃធម្មនុញ្ញតុងក្យូ និងមាត្រា II (១)(គ)នៃច្បាប់លេខ១០ របស់ក្រុមប្រឹក្សាត្រួតពិនិត្យ។ បទបញ្ញត្តិទាំងនេះគ្រប់ដណ្តប់អំពើនានា ដែលមិន ឬអាចមិនបង្កើតជាឧក្រិដ្ឋកម្មសង្គ្រាមក្នុងន័យចង្អៀត ប៉ុន្តែស្រដៀងគ្នានឹងឧក្រិដ្ឋកម្មសង្គ្រាមចំពោះលក្ខណៈអមនុស្សធម៌នៃបទល្មើសទាំងនេះ។ ជាទូទៅបទល្មើសទាំងនេះត្រូវបានយល់ថាជាអំពើនានា ដែលត្រូវបានប្រព្រឹត្តជាលក្ខណៈប្រព័ន្ធ និង*

[16] តុលាការឧក្រិដ្ឋកម្មសង្គ្រាមចិននៃក្រសួងការពារជាតិ ទីក្រុង Nanking ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៤៦ ក្នុង៖ របាយការណ៍ច្បាប់ស្តីពីការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម ជ្រើសរើស និងរៀបចំដោយគណៈកម្មការសហឧក្រិដ្ឋកម្មសង្គ្រាម ទីក្រុងឡុងដ៍ (ឆ្នាំ១៩៤៦) Volume XIV ឧបសម្ព័ន្ធ *អាចរកមើលបាននៅ* http://www.loc.gov/rr/frd/Military_Law/pdf/Law-Reports_Vol-14.pdf.

[17] *សូមមើល* ជើងទំព័រខាងលើ របាយការណ៍ច្បាប់ នៅទំព័រ ១៥៤-១៥៥។

*ច្រំដែលៗ និងជាទ្រង់ទ្រាយធំប្រឆាំងនឹងជនស៊ីវិល ក្នុងគោលបំណង ដូចជាឯកជនភាវូនីយកម្ម ដោយបង្ខំនៃប្រជាជាតិរហូតដល់ការសម្លាប់បំផុតពូជផ្នែកជីវសាស្ត្ររបស់ប្រជាជាតិនោះ"។*

២២. ឧទាហរណ៍នេះចង្អុលបង្ហាញថា ប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានប្រើប្រាស់ក្នុងតុលាការឧក្រិដ្ឋកម្មសង្គ្រាមជាតិមួយ ដើម្បីគ្របដណ្ដប់ឧក្រិដ្ឋកម្មដែលមានលក្ខណៈអមនុស្សធម៌ ហើយដែលមិនស្របទាំងស្រុងក្រោមបរិបទឧក្រិដ្ឋកម្មសង្គ្រាម។ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មសង្គ្រាមចិនបានដាក់បញ្ចូលគ្នានូវលក្ខន្តិកៈរបស់តុលាការតូក្យូ និងតុលាការNuremberg និងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង(ច្បាប់ជាតិចិន)។ ដូច្នេះ វិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏បានអនុញ្ញាតឱ្យធ្វើការផ្ដន្ទាទោសពីបទរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ។

២៣. ក្នុងសំណុំរឿងក្ដី *Takashi* ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចបានកំណត់ក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង គឺជាមូលដ្ឋានគតិយុត្តិសម្រាប់ការថ្កោលទោស។ ដូច្នេះ Takashi Sakai ត្រូវបានថ្កោលទោស និងកាត់ទោសប្រហារជីវិតចំពោះបទឧក្រិដ្ឋប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងក្នុងចំណោមបទល្មើសផ្សេងៗទៀតមានបទរំលោភសេពសន្ថវៈ ដែល (ត្រូវបានដាក់ ក្នុងបញ្ជី) ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ យើងខ្ញុំសូមដកស្រង់ចេញពីតុលាការទាំងនេះដូចខាងក្រោម៖

> *"ក្នុងការញុះញង់ ឬអនុញ្ញាតអ្នកក្រោមបង្គាប់របស់ខ្លួនឱ្យសម្លាប់ឈ្លើយសឹក ធ្វើឱ្យទាហាន គិលានុបដ្ឋាយិកា គ្រូពេទ្យកាកបាទក្រហម និងអ្នកមិនមែនជាយុទ្ធជនផ្សេងៗទៀតរងរបួស និងប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ លួចប្លន់ ជម្លៀស ធ្វើទារុណកម្ម និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ គាត់បានបំពារបំពានអនុសញ្ញាទីក្រុងឡាអេ ពាក់ព័ន្ធនឹងច្បាប់ និងទំនៀមទម្លាប់សង្គ្រាមតាមផ្លូវគោក និងអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩២៩។ បទល្មើសទាំងនេះជាឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[18] ។*

២៤. តុលាការនេះហាក់ដូចជាបែងចែកចំណាត់ថ្នាក់នៃច្បាប់ដែលពាក់ព័ន្ធទៅតាមក្រុមគោលដៅ៖ ជនជាប់ចោទត្រូវបានផ្ដន្ទាទោសពីឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រព្រឹត្តប្រឆាំងនឹងក្រុមមនុស្ស ដែលទទួលបាន

[18] *ដូចឯកសារខាងលើ* ទំព័រ៧។

ការការពារ ក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ/ឡាអេ ថាជាឧក្រិដ្ឋកម្មសង្គ្រាម ខណៈដែលអង្គហេតុផ្សេងៗទៀតមានដូចជា អំពើរំលោភសេពសន្ថវៈ អំពើលួចប្លន់ ការជម្លៀស និងអំពើទារុណកម្មត្រូវបានផ្តន្ទាទោស ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ នេះអាចដំណើរការទៅបាន ដោយព្រោះតែមូលដ្ឋានផ្លូវច្បាប់ដ៏ទូលំទូលាយ ដែលបានអនុម័តដោយតុលាការនេះ ក្នុងនោះរួមទាំងច្បាប់លេខ១០ របស់ ក្រុមប្រឹក្សាគ្រប់គ្រងផង។ ទោះជាយ៉ាងនេះក្តី សាលក្រមរបស់តុលាការនេះក៏បានគូសបញ្ជាក់ថា តុលាការនេះពុំបានបកស្រាយអំពីធាតុផ្សំផ្សេងៗនៃឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្ស ជាតិឡើយ។ នេះបញ្ជាក់ឲ្យឃើញអំពីរបៀបដែលចំណាត់ថ្នាក់ដែលពាក់នឹងគ្នាទាំងនេះមានលក្ខណៈ ជាន់គ្នា នៅគ្រានោះ[19]។

២៥. ក្នុងការជំនុំជម្រះរាប់ពាន់ករណីលើឧក្រិដ្ឋជនសង្គ្រាមនៅចុងបូព៌ា នៅប្រទេសចិន[20]តែឯង មានប្រមាណ៦០០ករណី។ រឿងក្តី *Takashi Sakai* បង្ហាញអំពីការប្រើប្រាស់មូលដ្ឋានផ្នែកច្បាប់ដែលដាក់បញ្ចូលគ្នាដ៏ទូលំទូលាយរបស់តុលាការឧក្រិដ្ឋកម្មសង្គ្រាមចិន ថាជាការចង្អុលបង្ហាញដ៏រឹងមាំបន្ថែមមួយទៀតថា អំពើរំលោភសេពសន្ថវៈ ដែលត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ កាលគ្រានោះ។

## ច្បាប់ជាតិស្តីពីបទរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មសង្គ្រាម ឬបើមិនដូច្នេះទេត្រូវបានហាមប្រាមក្នុងបរិបទសង្គ្រាម

២៦. ក្នុងអំឡុងរយៈពេលយុត្តាធិការរបស់ អ.វ.ត.ក ចាប់តាំងពីឆ្នាំ១៩៧៥ ដល់១៩៧៩ អំពើរំលោភសេពសន្ថវៈគឺជាបទឧក្រិដ្ឋ ស្ទើរតែទូទាំងពិភពលោកក្នុងចំណោមយុត្តាធិការជាតិ។ បន្ថែមលើនេះទៀត ក្នុងរយៈពេលបីទសវត្សរ៍បន្ទាប់ពីឆ្នាំ១៩៤៥មក ផ្នែកនីតិកម្មជាតិ និងសៀវភៅក្បួនយោធាមួយចំនួនបាន

---

[19] *សូមមើល* Askin, Kelly នៅទំព័រ១៣៨៖ "មានលក្ខណៈជាន់គ្នាដ៏សំខាន់រវាងបទចោទនៃឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"។

[20] *សូមមើល* មជ្ឈមណ្ឌលសិក្សាឧក្រិដ្ឋកម្មសង្គ្រាម http://socrates.berkley.edu/~warcrime/PT.htm។ មានតែសំណុំរឿង២២០ប៉ុណ្ណោះត្រូវបានវិភាគ។ សំណុំរឿងដែលនៅសេសសល់នៅបិទត្រានៅឡើយ។ អំពើហិង្សា/អំពើរំលោភសេពសន្ថវៈពុំមែនជាពាក្យពេចន៍គន្លឹះមួយក្នុងដំណើរការវិភាគឡើយ។

ប្រមូលចងក្រងបទឧក្រិដ្ឋនៃអំពើរំលោភសេពសន្ថវៈថា ជាការបំពារបំពានដ៏ធ្ងន់ធ្ងរនៃច្បាប់មនុស្សធម៌អន្តរជាតិ[21]។ អំពើរំលោភសេពសន្ថវៈត្រូវបានទទួលស្គាល់ថាជា ឧក្រិដ្ឋកម្មសង្គ្រាមក្នុងយុត្តាធិការជាតិជាច្រើននៅត្រឹមឆ្នាំ ១៩៧៥។

---

[21] *សូមមើល* http://www.icrc.org/customary-ihl/eng/docs/v2_rul_rule93។ សូមមើល ឧទាហរណ៍ **សៀវភៅក្បួនយោធា** - <u>អាហ្សង់ទីន (១៩៦៩)</u>: ច្បាប់ស្តីពីក្បួនសង្គ្រាមរបស់ប្រទេសអាហ្សង់ទីន (ឆ្នាំ១៩៦៩) ចែងថា៖ "ស្ត្រីនឹងត្រូវបានការពារជាពិសេសប្រឆាំងនឹងកិច្ចប៉ុនប៉ងទៅលើកិត្តិយសរបស់ពួកគេ ពិសេស ប្រឆាំងនឹងអំពើរំលោភសេពសន្ថវៈ អំពើពេស្យាចារដោយបង្ខំ និងការបំពានមិនសមរម្យ"។ * អាហ្សង់ទីន *Leyes de Guerra*, RC-46-1, Publico, II Edición 1969, Ejercito Argentino, Edición original aprobado por el Comandante en Jefe del Ejercito, ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ១៩៦៧ ជំពូក៤.០១០។ <u>ប្រទេសចិន (១៩៤៧)</u>៖ ប្រទេសចិន វិធានវិន័យ PLA: វិធានវិន័យ PLA (១៩៤៧) ចែងថា ស្ត្រីមិនត្រូវបានបំពានដោយអំពើអាសគ្រាមឡើយ។ * ចិន *បទបញ្ជាស្តីពីការប្រកាសឱ្យប្រើប្រាស់ឡើងវិញនូវវិធានចម្បងបីនៃវិន័យ និងចំណុចទាំងប្រាំបីសម្រាប់ការយកចិត្តទុកដាក់ពីទីបញ្ជាការនៃ PLA*, ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៧៤ ក្នុងច្បាប់ទី៤ សារព័ត៌មានប្រជាជន ទំព័រ១២៤១ ចំណុច៨។ <u>នីហ្សេរីយ៉ា(១៩៦៧)</u>៖ ក្រមសីលធម៌ប្រតិបត្តិ (១៩៦៧) នៃនីហ្សេរីយ៉ា ចែងថា៖ "ស្ត្រីនឹងត្រូវបានការពារពីការវាយប្រហារផ្សេងៗទៅលើរាងកាយ កិត្តិយស និងពិសេសពីអំពើរំលោភសេពសន្ថវៈ ឬរាល់ទម្រង់នៃការបំពានមិនសមរម្យ"។ * នីហ្សេរីយ៉ា *ក្រមសីលធម៌សម្រាប់កងកម្លាំងប្រដាប់អាវុធនីហ្សេរីយ៉ា* រដ្ឋាភិបាលយោធាសហព័ន្ធនៃនីហ្សេរីយ៉ា ចុះខែ កក្កដា ឆ្នាំ ១៩៦៧ ជំពូក៤ (ឈ)។ <u>ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង (១៩៥៨)</u>៖ ក្បួនយោធាចក្រភពអង់គ្លេស (១៩៥៨)ចែងថា៖ "ស្ត្រីត្រូវតែបានការពារយ៉ាងពិសេសពីរាល់ការវាយប្រហារទៅលើកិត្តិយសរបស់ពួកគេ ពិសេសពីអំពើរំលោភសេពសន្ថវៈ អំពើពេស្យាចារដោយបង្ខំ ឬរាល់ទម្រង់នៃការបំពានមិនសមរម្យនានា"។ យោងទៅតាមក្បួននេះ "ស្ត្រីចាំបាច់ត្រូវបានការពារយ៉ាងពិសេសពីរាល់ការបំពារបំពាននានាលើកិត្តិយសរបស់ពួកគេ ពិសេស ការរំលោភសេពសន្ថវៈ ពេស្យាចារដោយបង្ខំ ឬរាល់ទម្រង់នៃការបំពានមិនសមរម្យ"។ យោងទៅតាមក្បួននេះ វិធាននេះក៏ត្រូវយកទៅអនុវត្តផងដែរនៅក្នុងដែនដីដែលត្រូវបានកាន់កាប់។ ក្បួននេះក៏គូសបញ្ជាក់បន្ថែមទៀតថា ការបង្ខិតបង្ខំស្ត្រីឲ្យបម្រើក្នុងអំពើពេស្យាចារ បើទោះជាមិនត្រូវបានចាត់ទុកជាការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ក៏នៅតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាឧក្រិដ្ឋកម្មសង្គ្រាមដែរ។ * ចក្រភពអង់គ្លេស *ច្បាប់ស្តីពីសង្គ្រាមតាមដើងគោក ភាគ III នៃក្បួនច្បាប់យោធា ការិយាល័យទទួលបន្ទុកផ្នែកសឹកសង្គ្រាម* HMSO, ឆ្នាំ១៩៥៨ ជំពូក៣៩, ៥៤៧ និង៦២៦។ <u>សហរដ្ឋអាមេរិក (១៩៥៦)</u>៖ ក្បួនយោធាជើងគោករបស់សហរដ្ឋអាមេរិក (១៩៥៦) ចែងអំពីមាត្រា២៧នៃអនុសញ្ញា IV ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។ សហរដ្ឋអាមេរិក *ក្បួនយោធាជើងគោក ២៧-១០* ច្បាប់នៃគ្រឿងសព្វាវុធជើងគោក ក្រសួងយោធានៃសហរដ្ឋអាមេរិក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៥៦ ដូចបានកែសម្រួលដោយ Change លេខ១ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៦ ជំពូក២៦៦។ នីតិកម្មថ្នាក់ជាតិស្តីពីឧក្រិដ្ឋកម្មសង្គ្រាម - <u>អូស្ត្រាលី (១៩៤៥)</u>៖ ច្បាប់ស្តីពីឧក្រិដ្ឋកម្មសង្គ្រាមរបស់អូស្ត្រាលី (១៩៤៥)ចែងថា អំពើរំលោភសេពសន្ថវៈ និង "ការចាប់ពង្រាត់ក្មេងស្រី និងស្ត្រី សម្រាប់គោលបំណងបម្រើក្នុងអំពើពេស្យាចារដោយបង្ខំ" ជាឧក្រិដ្ឋកម្មសង្គ្រាម។ * អូស្ត្រាលី *ច្បាប់ស្តីពីឧក្រិដ្ឋកម្មសង្គ្រាម* ឆ្នាំ ១៩៤៥ ជំពូក៣។ <u>បង់ក្លាដែស (១៩៧៣)</u>៖ ច្បាប់(តុលាការ)ឧក្រិដ្ឋកម្មអន្តរជាតិ (១៩៧៣)

ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា
សុំឲ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

របស់បង់ក្លាដែស ចែងថា “ការបំពារបំពានរាល់វិធានមនុស្សធម៌ ដែលយកមកអនុវត្តក្នុងជម្លោះប្រដាប់អាវុធ ដូចមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩” គឺជាបទឧក្រិដ្ឋ។ * បង់ក្លាដែស ច្បាប់(តុលាការ)ឧក្រិដ្ឋកម្មអន្តរជាតិ (១៩៧៣) ជំពូក៣(២)(ង)។ ចិន(១៩៤៦)៖ ច្បាប់ចិនគ្របដណ្តប់លើការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម (១៩៤៦) ចែងថា អំពើសេពសន្ថវៈ និង “ការចាប់ពង្រាត់នារីភេទ ហើយបង្ខំពួកគេឲ្យធ្វើជាពេស្យាចារ” គឺជាឧក្រិដ្ឋកម្មសង្គ្រាម។ *ចិន ច្បាប់ចិនគ្របដណ្តប់លើការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាម ១៩៤៦ មាត្រា៣(៣) និង(១៧)។ ដាណឺម៉ាក (១៩៧៧)៖ ជនណាដែលប្រើប្រាស់ឧបករណ៍ ឬនីតិវិធីសង្គ្រាម ដែលការអនុវត្តនោះបំពារបំពានលើកិច្ចព្រមព្រៀងអន្តរជាតិ ដែលចុះហត្ថលេខាផ្តល់សុពលភាពដោយប្រទេសដាណឺម៉ាក ឬវិធានទូទៅនៃច្បាប់អន្តរជាតិ នឹងត្រូវទទួលទោសដូចគ្នា (ឧ. ប្រាក់ផាកពិន័យ ការជាប់ពន្ធនាគារកម្រិតស្រាល ឬរហូតដល់ការជាប់ពន្ធនាគាររយៈពេល ១២ឆ្នាំ)។ * ដាណឺម៉ាក ក្រមព្រហ្មទណ្ឌយោធា (១៩៧៣) វិសោធនកម្មឆ្នាំ១៩៧៨ ជំពូក២៥(១)។ អេត្យូពី (១៩៥៧)៖ ក្រោម ក្រមព្រហ្មទណ្ឌរបស់អេត្យូពី (១៩៥៦) “ការបង្ខិតបង្ខំឲ្យបម្រើក្នុងអំពើពេស្យាចារ អំពើអនាចារ និងអំពើរំលោភសេពសន្ថវៈ” ជាឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងប្រជាជនស៊ីវិល។ * អេត្យូពី ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៧ មាត្រា២៨២(ច)។ ហុងគ្រី (១៩៧៨)៖ ក្រោម ក្រមព្រហ្មទណ្ឌរបស់ប្រទេសហុងគ្រី (១៩៧៨) វិសោធនកម្មឆ្នាំ ១៩៩៨ ចាត់វិធានការបង្ការនូវកំណើតនៅក្នុងក្រុមសាសនា ជាតិសាសន៍ ជាតិពន្ធុ ឬជាតិមួយ ថាជាផ្នែកមួយនៃយុទ្ធនាការអំពើប្រល័យពូជសាសន៍ បង្កើតជា “ឧក្រិដ្ឋកម្មប្រឆាំងនឹងសិទ្ធិសេរីភាពរបស់មនុស្ស”។ * ហុងគ្រី ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៧៨ វិសោធនកម្មឆ្នាំ ១៩៩៨ ជំពូក ១៥៥(១)(ឃ)។ អៀរឡង់ (១៩៦២)៖ ច្បាប់អនុសញ្ញាទីក្រុងហ្សឺណែវរបស់អៀរឡង់ (១៩៦២) វិសោធនកម្មឆ្នាំ ១៩៩៨ ចែងថា រាល់ “ការបំពារបំពានតូចតាច”លើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ក្នុងនោះរួមទាំង ការបំពារបំពានលើមាត្រា៣ និង២៧នៃអនុសញ្ញា IVទីក្រុងហ្សឺណែវ ឆ្នាំ ១៩៧៧ ពិធីសារបន្ថែម I ក្នុងនោះរួមមាន ការបំពារបំពានលើមាត្រា៧៥(២), ៧៦(១) និង ៧៧(១) ក៏ដូចជា ការបំពារបំពានមាត្រា៤(២)(ង) គឺជាបទល្មើសដែលត្រូវទទួលទោសទណ្ឌ។ * អៀរឡង់ ច្បាប់អនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៦២ វិសោធនកម្មឆ្នាំ ១៩៩៨ ជំពូក៤(១) និង(៤)។ អ៊ីស្រាអែល (១៩៥០)៖ ច្បាប់(ដាក់ទោស)ពួកអ្នកធ្វើសហប្រតិបត្តិការជាមួយពួកណាហ្ស៊ី និងពួកណាហ្ស៊ីរបស់ប្រទេសអ៊ីស្រាអែល (១៩៥០) ក្នុងនោះរាប់ទាំង “ការដាក់ចេញនូវវិធានការក្នុងគោលបំណងបង្ការមិនឲ្យមានកំណើតក្នុងចំណោមជនជាតិជ្វីហ្វ” ក្នុងខ្លឹមសារនៃអំពើប្រល័យពូជសាសន៍។ *អ៊ីស្រាអែល ច្បាប់(ដាក់ទោស)ពួកអ្នកធ្វើសហប្រតិបត្តិការជាមួយពួកណាហ្ស៊ី និងពួកណាហ្ស៊ី ឆ្នាំ ១៩៥០ ជំពូក១(ខ)។ លីទុយអានី (១៩៦១)៖ ក្រោម ក្រមព្រហ្មទណ្ឌរបស់ប្រទេសលីទុយអានី (១៩៦១) វិសោធនកម្មឆ្នាំ ១៩៩៨ “អំពើរំលោភសេពសន្ថវៈលើនារីភេទ ឬបង្ខិតបង្ខំពួកគេឲ្យបម្រើក្នុងអំពើពេស្យាចារ” បង្កើតជាឧក្រិដ្ឋកម្មសង្គ្រាម។ * លីទុយអានី ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៦១ វិសោធនកម្ម ឆ្នាំ ១៩៩៨ មាត្រា៣៣៦។ ភូមា (១៩៥៩)៖ ច្បាប់សេវាការពារជាតិរបស់ប្រទេសភូមា (១៩៥៩) ចែងថា៖ ជនណាដែលស្ថិតនៅក្រោមច្បាប់នេះ ហើយប្រព្រឹត្តបទល្មើស ... អំពើរំលោភសេពសន្ថវៈ ទាក់ទិននឹង (ជនដែលមិនស្ថិតនៅក្រោមច្បាប់យោធា) នឹងពុំមានពិរុទ្ធពីបទល្មើសប្រឆាំងនឹងច្បាប់នេះឡើយ ហើយមិនត្រូវជំនុំជម្រះដោយតុលាការសឹកឡើយ ប្រសិនបើបុគ្គលនោះពុំបានប្រព្រឹត្តបទល្មើសដូចរៀបរាប់ខាងលើទេនោះ... ក្នុងអំឡុងពេលបម្រើសកម្មក្នុងយោធា។ *ភូមា *ច្បាប់សេវាការពារជាតិ* ឆ្នាំ ១៩៥៩ ជំពូក១៩៧២។ ហូឡង់ (១៩៤៦)៖ អត្ថន័យនៃក្រឹត្យឧក្រិដ្ឋកម្មសង្គ្រាម (១៩៤៦)នៃប្រទេសហូឡង់ រួមបញ្ចូលនូវ “អំពើរំលោភសេពសន្ថវៈ” និង “ការចាប់ពង្រាត់ក្មេងស្រី និងស្ត្រី ក្នុងគោលបំណងឲ្យបម្រើក្នុងអំពើពេស្យាចារដោយបង្ខំ” ក្នុងបញ្ជីនៃឧក្រិដ្ឋកម្មសង្គ្រាម។ * ហូឡង់ *អត្ថន័យនៃក្រឹត្យឧក្រិដ្ឋកម្ម*

## លក្ខខណ្ឌតម្រូវនៃការផ្តន្ទាទោស ក្រោមច្បាប់*លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង*

២៧. អង្គបុរេជំនុំជម្រះរកឃើញថា ដំណើរដែលគ្មានការផ្តន្ទាទោសអំពើរំលោភសេពសន្ថវៈ ក្នុងច្បាប់លេខ ១០ គឺជាទឡ្ហីករណ៍មួយដែលការកំណត់អំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ គឺពុំគ្រប់គ្រាន់ឡើយ[22]។

២៨. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមជំទាស់ទៅនឹងទឡ្ហីករណ៍នេះ ដោយផ្អែកទៅលើសំអាងហេតុតែម្តង។ ការប្រមូលចងក្រងនៃអំពើរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋដែលមានឈ្មោះក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ *តែមួយ* បង្ហាញអំពីទស្សនៈរបស់សហគមន៍អន្តរជាតិដែលថា អំពើរំលោភសេពសន្ថវៈត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ អង្គហេតុដែលថាពុំមានការផ្តន្ទាទោសណាមួយអាចត្រូវបានបកស្រាយពន្យល់ដោយកត្តាផ្សេងៗនោះ ក្នុងនោះរួមមានអង្គហេតុដែលថា អ្នកដែលទទួលខុសត្រូវចំពោះយុទ្ធសាស្ត្រផ្នែករដ្ឋអាជ្ញាសុទ្ធតែជាបុរស ដែលមានការស្ទាក់ស្ទើរជាទូទៅក្នុងការដោះស្រាយនឹងករណីរំលោភសេពសន្ថវៈនៅគ្រានោះ និងមានទស្សនៈរួមមួយដែលថា វាចាំបាច់ជាងក្នុងការផ្តន្ទាទោសបទឧក្រិដ្ឋនានា ដូចជា ការសម្លាប់ទ្រង់ទ្រាយធំ ជាជាងអំពើរំលោភសេពសន្ថវៈដែលត្រូវបានអនុវត្តប្រឆាំង "តែ" នឹងស្ត្រីភេទនោះ។ បន្ថែមលើនេះទៀត ភាពអាម៉ាស់ និងភាពស្ងាត់

---

*សង្គ្រាម* ឆ្នាំ ១៩៤៦ មាត្រា១។ នីហ្សេ (១៩៦១)៖ យោងទៅលើ ក្រមព្រហ្មទណ្ឌរបស់ប្រទេសនីហ្សេ (១៩៦១) វិសោធនកម្មឆ្នាំ ២០០៣ វាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក្នុងការចាត់ "វិធានការ ក្នុងបំណងបង្ការកំណើត" ក្នុងក្រុមមួយ ជាមួយនឹងចេតនាក្នុងការបំផ្លិចបំផ្លាញជាចំណែក ឬទាំងស្រុងនៃក្រុមសាសនា ជាតិសាសន៍ ជាតិពន្ធុ ឬជាតិមួយ ឬក្រុមមួយដែលត្រូវបានកំណត់ដោយឈរលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យតាមទំនើងចិត្តផ្សេងៗទៀត។ * នីហ្សេ ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៦១ ធ្វើវិសោធនកម្មឆ្នាំ២០០៣ មាត្រា២០៨.១។ សាធារណរដ្ឋកុងហ្គោ (១៩៦២)៖ ក្រមព្រហ្មទណ្ឌយោធារបស់សាធារណរដ្ឋកុងហ្គោ (១៩៦២) ចែងថា ការរំលោភលើនារីភេទ ក្នុងពេលមានការវាយប្រយុទ្ធ ឬក្នុងតំបន់កាន់កាប់នឹងទទួលរងការផ្តន្ទាទោសប្រហារជីវិត។ *សាធារណរដ្ឋកុងហ្គោ ក្រមព្រហ្មទណ្ឌយោធា ឆ្នាំ ១៩៦២ មាត្រា៨៤(១)។ យូហ្គោស្លាវី (១៩៤៥)៖ បទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងជាតិ និងច្បាប់រដ្ឋ (១៩៤៥) របស់សាធារណរដ្ឋសហព័ន្ធសង្គមនិយមយូហ្គោស្លាវី ចែងថា ក្នុងអំឡុងពេលសង្គ្រាម ឬការកាន់កាប់របស់ខ្មាំងសត្រូវ "ចំពោះជនណាដែលចេញបញ្ជា ទំនុកបម្រុង ឬពុំនោះទេជាអ្នកប្រព្រឹត្តផ្ទាល់នៃ...អំពើពង្រាត់សម្រាប់ពេស្យាចារកម្ម ឬការរំលោភសេពសន្ថវៈ" បានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម។ * សាធារណរដ្ឋ សហព័ន្ធ សង្គមនិយមយូហ្គោស្លាវី បទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងជាតិ និងច្បាប់រដ្ឋ (ឆ្នាំ១៩៤៥) មាត្រា៣(៣)។

[22] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ D427/1/30 កថាខណ្ឌ៣៦៨។

ស្តៀមជុំវិញបទឧក្រិដ្ឋផ្លូវភេទជាកត្តាមួយ ដែលធ្វើឲ្យការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋផ្លូវភេទ មានលក្ខណៈមិនសូវជាទំនងនោះទេ។ មានការរើសអើងជាច្រើនទាក់ទិននឹងបទឧក្រិដ្ឋផ្លូវភេទ ហើយដែលរួមចំណែកដល់ការមិនយកចិត្តទុកដាក់ទៅលើបទឧក្រិដ្ឋប្រភេទនេះនៅគ្រានោះ[23]។ Askin មានការកត់សម្គាល់ទៀតថា "ប្រទេសសម្ព័ន្ធមិត្តចង់ដាក់កម្រិតដល់ការផ្តន្ទាទោសពួកណាហ្ស៊ី និងជប៉ុន ចំពោះបទឧក្រិដ្ឋនានា ដែលមិនត្រូវបានប្រព្រឹត្តដូចគ្នានេះដែរដោយកងទ័ពរបស់ប្រទេសសម្ព័ន្ធមិត្ត ជាអាទិ៍ មានការសម្លាប់បំផុតពូជទ្រង់ទ្រាយធំ និងបទឧក្រិដ្ឋប្រឆាំងនឹងសន្តិភាព និងពុំមែនជាបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តជាទូទៅដោយប្រទេសសម្ព័ន្ធមិត្ត និងកងទ័ពរបស់ពួកប្រទេសសម្ព័ន្ធមិត្តដូចគ្នាដែរនោះ ដែលគួរឲ្យកត់សម្គាល់ជាងគេនោះគឺ បទឧក្រិដ្ឋរំលោភសេពសន្ថវៈ"[24]។

២៩. ក្នុងរឿងក្តីប្រឆាំងនឹង *Gaertner* ក្នុងចំណោមបទចោទផ្សេងៗទៀត ត្រូវបានចោទពីបទរំលោភសេពសន្ថវៈដែលបានប្រព្រឹត្តក្នុងជំរុំប្រមូលផ្តុំរបស់ពួកណាហ្ស៊ីឈ្មោះជំរំ Sachsenhausen ថាជាឧក្រិដ្ឋកម្មសង្គ្រាម ក្រោមច្បាប់ លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង។ ក្នុងរឿងក្តីនេះ តុលាការ *Tribunal Supérieur de la Haute Commission Alliée en Allemagne à Rastatt* បានតម្កល់សេចក្តីសម្រេចដែលថា ចុងចោទមិនត្រូវបានផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈ ដោយឈរលើមូលដ្ឋានដែលថាពុំមានភស្តុតាងផ្ទាល់ពីជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ ដូច្នេះហើយពុំមានភស្តុតាងគ្រប់គ្រាន់សម្រាប់ការផ្តន្ទាទោសនេះ[25]ឡើយ។

៣០. យើងអាចទាញហេតុផលចេញពីរឿងក្តីប្រឆាំងនឹង *Gaertner* បានថា ក្នុងករណីអំពើហិង្សាផ្លូវភេទ កង្វះខាតនៃសក្ខីកម្មនៃជនរងគ្រោះដែលនៅរស់រានមានជីវិត មានលក្ខណៈជាទូទៅ។ ជាលទ្ធផល បើទោះជាត្រូវបានផ្តន្ទាទោសក្តី ក៏ពុំមានការសម្រេចថ្កោលទោសដែរ។

---

[23] Askin, Kelly, ឧក្រិដ្ឋកម្មសង្គ្រាមប្រឆាំងនឹងស្ត្រី ទីក្រុងឡាអេ (ឆ្នាំ១៩៩៧) ជើងទំព័រ៣១៤។

[24] Askin, ទំព័រ១៦៣។

[25] សំណុំរឿងក្តីប្រឆាំងនឹង *Gaertner, Johann*, Haut Commissaireat de la Republique Français en Allemagne, Tribunal Supérieur de la Haute Commission Alliée en Allemagne, Jugement en Matière d'Appel, ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ១៩៥០ ឯកសារលេខ 332/904 ទំព័រ៥។

៣១. ដោយពុំគិតអំពីមូលហេតុនៃកង្វះខាតការសម្រេចថ្កោលទោសនោះ វានៅតែជាករណីដែលថា អំពើរំលោភសេពសន្ថវៈត្រូវបានចុះក្នុងបញ្ជីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រងដោយឆ្លុះបញ្ចាំងអំពីការយល់ដឹងជាអន្តរជាតិ អំពីភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋរំលោភសេពសន្ថវៈ និងចរិតលក្ខណៈដ៏សមស្របរបស់វា នៅគ្រានោះ។

## បទរំលោភសេពសន្ថវៈដែលស្ថិតខាងក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ

៣២. ទាំង ក.ស.ព ក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន និង ក.ស.ច.ស ក្នុងដីកាដំណោះស្រាយរបស់ខ្លួនបានរកឃើញថា ករណីអំពើរំលោភសេពសន្ថវៈមួយចំនួនត្រូវបានប្រព្រឹត្តនៅតាមមន្ទីរសន្តិសុខ និងសហករណ៍ ដែលស្ថិតនៅខាងក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ[26]។ ទោះជាយ៉ាងនេះក្តី ក.ស.ច.ស មិនបានចោទប្រកាន់ករណីទាំងនេះឡើយ ដោយយល់ឃើញថា គោលនយោបាយជាផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ គឺបង្ការបទឧក្រិដ្ឋនេះ និងដាក់ទណ្ឌកម្មដល់ចារី" ហើយថា "ក៏គេមិនអាចចាត់ទុកជាការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រើប្រាស់ដោយបក្សកុម្មុយនីស្តកម្ពុជាក្នុងការដាក់ឱ្យអនុវត្តនូវផែនការរួមឡើយ"[27]។

៣៣. ទោះជាយ៉ាងណាក៏ដោយ មានភស្តុតាង[28] បង្ហាញថា ចារីមិនត្រូវបានដាក់ទោសចំពោះអំពើរំលោភសេពសន្ថវៈឡើយ ប្រសិនបើពួកគេជាអ្នកបដិវត្តន៍ល្អៗ។ យ៉ាងហោចណាស់មានមួយករណី នៅពេលដែល សុន សេន សមាជិកបម្រុងនៃគណៈអចិន្ត្រៃយ៍ ឬ នួន ជា សមាជិកអចិន្ត្រៃយ៍នៃគណៈអចិន្ត្រៃយ៍

---

[26] *សូមមើល* ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១០ ឯកសារលេខ D390 កថាខណ្ឌ 382, 410, 470, 485, 506, 580, 656 & 768។ *ក៏សូមមើល* ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427 កថាខណ្ឌ១៤២៦។

[27] *ដូចឯកសារខាងលើ* កថាខណ្ឌ១៤២៨។

[28] *សូមមើល* សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំដាក់ឯកសារបញ្ចូលក្នុងសំណុំរឿងពាក់ព័ន្ធនឹងបទល្មើសរំលោភសេពសន្ថវៈនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៩ ឯកសារលេខ D190 និង ឧបសម្ព័ន្ធប្រាំ។ សេចក្តីថ្លែងការណ៍សាក្សី អៀប ឌុច របស់ ក.ស.ច.ស ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៧ ឯកសារលេខ D25/28 (ទំព័រ១០) និងសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីអំពីការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១០ ឯកសារលេខ D348 កថាខណ្ឌ១៥-១៩ សំអាងទៅសំណុំរឿង០០១។ *ក៏សូមមើល* ឯកសារលេខ E9/32។

ទទួលព័ត៌មានអំពីការរំលោភសេពសន្ថវៈនៅមន្ទីរស-២១ ប៉ុន្តែពុំបានចេញបញ្ជាឲ្យមានការដាក់ទណ្ឌកម្មណាមួយដល់ចារីឡើយ[29]។ បន្ថែមលើនេះទៀត សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសង្កេតឃើញថា ដីកាដំណោះស្រាយកត់សម្គាល់ថា ក្នុងចំណោមរឿងផ្សេងៗទៀត គោលបំណងរួមនៃបក្សកុម្មុយនីស្តកម្ពុជា គឺដើម្បី "ការពារបក្សពីខ្មាំងខាងក្រៅ និងខាងក្នុង *តាមមធ្យោបាយអ្វីក៏ដោយ បើចាំបាច់*"[30] (គូសបញ្ជាក់បន្ថែម)។

៣៤. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមរំឭកថា អង្គហេតុពាក់ព័ន្ធនឹងតែរឿងក្តីនៃអំពើហិង្សា និងការរំលោភសេពសន្ថវៈផ្លូវភេទតែមួយចំនួនតូចប៉ុណ្ណោះ ពិសេសដូចមានក្នុងដីកាដំណោះស្រាយ។ ករណីទាំងនេះត្រូវបានរាយការណ៍ពីមន្ទីរស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខភូមិភាគឧត្តរ ព្រៃដំរីស្រុត គុកសង់ និងសហករណ៍ត្រាំកក់[31]។ ក្នុងចំណោមករណីទាំងនេះ មានតែនារីម្នាក់ប៉ុណ្ណោះ ដែលជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈនៅមន្ទីរស-២១[32] នៅរស់រានមានជីវិត។ បច្ចុប្បន្ននេះ នាងត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ បើទោះជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ត្រូវបានបដិសេធចោល ក្នុងសំណុំរឿង០០១ក៏ដោយ[33]។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សេចក្តីថ្លែងការណ៍ថ្មីៗ[34] ជំនួសគាត់ជាមួយនឹងចេតនាក្នុងការរួមចំណែកទៅនឹង ការវាយតម្លៃរបស់អង្គជំនុំជម្រះសាលាដំបូងលើសំអាងហេតុពាក់ព័ន្ធនឹងការទទួលខុសត្រូវ ក្នុងដីកាដំណោះស្រាយ។ សេចក្តីថ្លែងការណ៍ទាំងនេះចង្អុលបង្ហាញថា ស្ត្រីដែលត្រូវបានចាត់ទុកជា "ខ្មាំង" និង/ឬ "សមាសភាពមិនល្អ" រួចហើយនោះ ជាញឹកញាប់ ពួកគេត្រូវបានរំលោភមុននឹងយកទៅសម្លាប់។ គ្រប់ករណីទាំងអស់ ការរំលោភសេពសន្ថវៈមិនមានអ្វីលាក់កំបាំងឡើយ ហើយជាផ្នែកមួយនៃការដឹងឮជារួមនៃសហគមន៍នៅជុំវិញ និងត្រូវបានដឹងឮដោយថ្នាក់ដឹកនាំពាក់ព័ន្ធ។

---

29 *សូមមើល* រឿងក្តីប្រឆាំងនឹង កាំង ហ្កេកអ៊ាវ សាលាក្រម ឯកសារ E188 កថាខណ្ឌ២៤៦។

30 *ដូចឯកសារខាងលើ* កថាខណ្ឌ១៥៨។

31 *សូមមើល* ដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារលេខ D427 កថាខណ្ឌ១៤២៦។

32 *ដូចឯកសារខាងលើ* កថាខណ្ឌ៤៥៨។

33 រឿងក្តីនេះកំពុងស្ថិតក្រោមចំណាត់ការរបស់អង្គជំនុំជម្រះតុលាការកំពូល។

34 បញ្ជីឈ្មោះឯកសារ និងវត្ថុតាង (ឧបសម្ព័ន្ធ៧ និង៨)របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E9/32។

៣៥. អំពើរំលោភសេពសន្ថវៈអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវដោយជនជាប់ចោទ ដោយសារតែការខកខានមិនបានគ្រប់គ្រងអ្នកនៅក្រោមបង្គាប់របស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងការខកខានមិនបានអនុវត្តនូវវិធានការសមហេតុផល និងចាំបាច់នានា។ បើទោះជាមេកោយរបស់ចារីបានដឹងអំពីអត្ថិភាពនៃការរំលោភសេពសន្ថវៈក៏ដោយ ក៏ពួកគេពុំបានដាក់ទោសចារីដែរ។ ទាំងសម្លាប់ និងទាំងការរំលោភសេពសន្ថវៈមិនត្រូវបានទទួលទោសទណ្ឌអ្វីដែរ ដោយសារតែបទឧក្រិដ្ឋទាំងពីរនេះជាផ្នែកនៃគោលនយោបាយប្រើប្រាស់ប្រឆាំងនឹងខ្មាំង។ ជនជាប់ចោទអាចដឹងថា អ្នកក្រោមបង្គាប់របស់ខ្លួនបានប្រព្រឹត្តការរំលោភសេពសន្ថវៈទាំងនេះ ហើយនៅតែខកខានមិនបានដាក់ទោសទណ្ឌពួកគេ។ សេចក្តីថ្លែងការណ៍ថ្មីៗទាំងនេះនឹងរួមចំណែកក្នុងការជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់ ក.ស.ច.ស ក្នុងដីកាដំណោះស្រាយ[35] ដែលថាអំពើរំលោភសេពសន្ថវៈដែលស្ថិតនៅខាងក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ មិនអាចត្រូវបានផ្សារភ្ជាប់ទៅនឹងជនជាប់ចោទបាន ដោយសារតែមានគោលនយោបាយក្នុងការដាក់ទោសទណ្ឌការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទនោះ។

៣៦. បន្ថែមលើនេះទៀត ដីកាដំណោះស្រាយចែងថា៖

> "*កម្មាភិបាលនៃមន្ទីរសន្តិសុខទាំងនេះដឹងថា ការរំលោភផ្លូវភេទគឺជាបទល្មើសដែលខ្លួនអាចទទួលរងទណ្ឌកម្ម ឧទាហរណ៍ដូចជា នៅមន្ទីរសន្តិសុខ ក្រាំងតាចាន់ ជាដើម។ លើសពីនេះ ជួនកាលកម្មាភិបាល ប.ក.ក បានទទួលការណែនាំឱ្យស៊ើបអង្កេតលើករណីរំលោភផ្លូវភេទនៅតាមសន្តិសុខនានា ដូចជា នៅមន្ទីរសន្តិសុខក្រាំងតាចាន់*"[36]។

៣៧. សេចក្តីថ្លែងការណ៍នេះគឺមិនត្រឹមត្រូវឡើយ។ វិធីសាស្ត្ររបស់ពួកខ្មែរក្រហមពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មផ្លូវភេទ ដូចដែលពណ៌នាក្នុងសេចក្តីថ្លែងការណ៍នេះ ពុំមែនជាការតំណាងដ៏ត្រឹមត្រូវនៃគោលនយោបាយដែលត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជាក្នុងចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ឡើយ។ ក្រោយមកទៀត សេចក្តីសន្និដ្ឋានធ្វើឡើងដោយ ក.ស.ច.ស ដែលថា មានគោលនយោបាយនៃការផ្តន្ទាទោស និងដាក់ទណ្ឌកម្មចំពោះអំពើហិង្សាផ្លូវភេទគឺមិនពិតឡើយ។

---

[35] ដីកាដំណោះស្រាយ ឯកសារលេខ D427 កថាខណ្ឌ១៤២៨។

[36] ដីកាដំណោះស្រាយ ឯកសារលេខ D427 កថាខណ្ឌ១៤២៨។

៣៨. សហចៅក្រមស៊ើបអង្កេត (ស.ច.ស) បានលុបចោលអង្គហេតុដែលថា នៅមន្ទីរសន្តិសុខសង់ ចារីត្រូវបានឃុំខ្លួនតែក្នុងរយៈពេលមួយសប្តាហ៍ ហើយក៏ត្រូវបានដោះលែងវិញ[37]។ នេះមិនអាចត្រូវបានចាត់ទុកជា "ការដាក់ទណ្ឌកម្ម" ឡើយ បើប្រៀបធៀបទៅនឹងបទឧក្រិដ្ឋដែលបានប្រព្រឹត្ត ឬបង្ហាញអំពីចេតនាក្នុងការផ្ទុះបញ្ចាំងនូវគោលនយោបាយរដ្ឋចំពោះការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ។ បន្ថែមលើនេះទៀត យោងទៅតាមសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី[38] ចារីទាំងនេះបានបន្តកាន់មុខតំណែងរបស់ខ្លួនដដែល បន្ទាប់ពីការដោះលែង ហើយប្រើប្រាស់អំណាចរបស់ខ្លួន ដោយចេញបញ្ជាថា ជនរងគ្រោះពីអំពើរំលោភសេពសន្ថវៈត្រូវបង្អត់អាហារ។ ជាលទ្ធផល ជនរងគ្រោះបង្អត់អាហារ និងត្រូវទទួលទណ្ឌកម្មប្រកបដោយប្រសិទ្ធភាពទ្វេដង។

៣៩. ក្នុងដីកាដំណោះស្រាយ មានចែងយ៉ាងច្បាស់ថា បទចោទស្តីពីបទរំលោភសេពសន្ថវៈត្រូវបានស៊ើបអង្កេតនៅមន្ទីរសន្តិសុខក្រាំងតាចាន់[39]។ ទោះជាយ៉ាងនេះក្តី ដីកាដំណោះស្រាយពុំបានគូសបញ្ជាក់ថា បន្ទាប់ពីការស៊ើបអង្កេតនោះ ប្រធានគុកដែលរៀបចំការស៊ើបអង្កេតប្រឆាំងនឹងចារីរូបនោះបានលើកលែងទោសវិញ ដោយសារតែសកម្មភាពបដិវត្តន៍របស់គេ[40]។ ដូច្នេះ ពុំមានការដាក់ទណ្ឌកម្មអ្វីឡើយ។

៤០. ការលុបចោលនូវអង្គហេតុដែលបានកើតឡើង នាំឱ្យ ស.ច.ស ធ្វើសេចក្តីសន្និដ្ឋានដោយខុសថា ការដាក់ទណ្ឌកម្មចំពោះអំពើរំលោភសេពសន្ថវៈ គឺជាគោលនយោបាយរបស់ពួកខ្មែរក្រហម។ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមធ្វើសេចក្តីសន្និដ្ឋានថា សំអាងហេតុរបស់ ស.ច.ស ដែលពុំបានផ្តន្ទាទោសជនជាប់ចោទចំពោះអំពើរំលោភសេពសន្ថវៈ ដែលស្ថិតនៅក្រៅបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំគឺមានការភ័ន្តច្រឡំ ដូច្នេះហើយ វាចាំបាច់ណាស់ក្នុងការកំណត់បទចោទសាជាថ្មីលើអង្គហេតុនានាក្នុងដីកាដំណោះស្រាយ។

---

[37] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឃិន សុខ របស់ ក.ស.ច.ស ឯកសារលេខ D277/3 ទំព័រទី៨ និង កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឈុំ ណួត របស់ ក.ស.ច.ស ឯកសារលេខ D277/4 ទំព័រទី៨ និង៩។

[38] *ដូចឯកសារខាងលើ។*

[39] *សូមមើល* កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀប ឌុច របស់ ក.ស.ច.ស ឯកសារលេខ D25/28។

[40] *ដូចជើងទំព័រខាងលើ។*

៤១. បន្ថែមលើនេះទៀត សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសូមយល់ស្របជាមួយនឹងការវាយតម្លៃរបស់ ក.ស.ព ដែលថា "ឧក្រិដ្ឋកម្មបែបនេះ គឺជាផលវិបាកដែលគេអាចទាយទុកជាមុនបានអំពីសហឧក្រិដ្ឋកម្មរួម ដោយហេតុថា វាមានការពាក់ព័ន្ធនឹងការបាត់បង់ភាពជាមុនស្ស ការធ្វើទារុណកម្ម និងការបន្ទាបបន្ថោកដោយគិតទុកជាមុនចំពោះមនុស្សដែលគេហៅថា "ពួកសមាសសភាពមិនល្អ"[41]។

## សេចក្ដីសន្និដ្ឋាន

៤២. សរុបសេចក្ដីមក ក្រោមយុត្តាធិការពេលវេលារបស់ អ.វ.ត.ក អំពើរំលោភសេពសន្ថវៈគួរត្រូវបានធ្វើចំណាត់ថ្នាក់ឲ្យបានត្រឹមត្រូវថា ជាអនុឧក្រិដ្ឋកម្មដូចដែលបានរៀបរាប់ ដាច់ដោយឡែកមួយ នៅពេលត្រូវបានផ្ដន្ទាទោសថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

៤៣. សំអាងហេតុនៃការទទួលខុសត្រូវចំពោះអំពើរំលោភសេពសន្ថវៈដែលស្ថិតនៅក្រៅបរិបទ នៃអាពាហ៍ពិពាហ៍ដោយបង្ខំគួរត្រូវបានកំណត់បទចោទសាជាថ្មី ដើម្បីឆ្លុះបញ្ចាំងអំពីការប្រើប្រាស់អំពើរំលោភសេពសន្ថវៈជាចំណែកមួយនៃ "គោលនយោបាយប្រើប្រាស់ប្រឆាំងនឹងខ្មាំងសត្រូវ"។

## III. សំណើ

៤៤. សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងឲ្យ៖

(i) កំណត់អំពើរំលោភសេពសន្ថវៈសាជាថ្មីថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្របទៅតាមលក្ខណៈរបស់វា

(ii) កំណត់សំអាងហេតុនៃការទទួលខុសត្រូវសាជាថ្មីចំពោះអំពើរំលោភសេពសន្ថវៈដែលស្ថិតនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និង

(iii) ជូនដំណឹងដល់ជនជាប់ចោទអំពីការកំណត់បទចោទសាជាថ្មីនេះ។

---

[41] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E99 កថាខណ្ឌ៣២។

សូមអង្គជំនុំជម្រះសាលាដំបូងទទួលយកចម្លើយតបនេះដោយក្ដីគោរព។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១១ | **លោក ពេជ អង្គ**<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | |
| | **លោកស្រី Elisabeth SIMONNEAU FORT**<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |
| | Silke STUDZINSKI<br>សហមេធាវីអន្តរជាតិ | ភ្នំពេញ | |
| | ស៊ិន សុវ៉ន<br>សហមេធាវីជាតិ | ភ្នំពេញ | |